# ក្នុងនាមឈាមខ្មែរ

(បទពាក្យ៧)

កើតមកក្នុងនាមឈាមខេមរា   តពង្សាវតាកោះគោកធ្លក
មានឈ្មោះជាខ្មែរហូរហែមក   មានដីរស់ជ្រកមានភាសា ។
មានទាំងវប្បធម៌ប្រពៃណី   សិល្បៈសោភីល្អអស្ចារ្យ
ទំនៀមទំលាប់ក្បួនសាស្ត្រា   មានពុទ្ធសាសនាថ្លៃអនេក ។
មរតកបុរាណមានហែហូរ   ប្រាសាទអង្គរបវរឯក
ក្បូរក្បាច់ចម្លាក់គន់គាប់ភ្នែក   ជាទីត្រាច់ត្រេកនៃទេសចរ ។
លក្ខណៈជាតិខ្មែរមានបរិបូណ៌   កូនខ្មែរថៃ មក៏ ជាតំណ
ក្បួនច្បាប់សីលធម៌សុទ្ធបវរ   សំរាប់លំអកេរ្តិ៍ខេមរា ។
កូនខ្មែរប្រុសស្រីគប្បីដឹង   គន់គិតរំពឹងកុំសង្កា
ទោះនៅដីខ្មែរឬទីណា   មានឈាមខេមរាឈ្មោះថាខ្មែរ ។
ដឹងឫសដឹងគល់យល់ដើមដាន   អោយជាក់កុំស្មានកុំគេចកែ
កុំគិតថានេះរឿងឪម៉ែ   រូបខ្ញុំនេះនៃកើតស្រុកគេ ។
ច្រើនជាតិច្រើនសាសន៍ប្រាសទឹកដី   ជ្រកក្នុងឋានថ្មីដូចគ្នាទេ
គេចេះរក្សាចិត្តឥតរេ   ចេះគិតគ្នាន់គ្នេរលក្ខណៈជាតិ ។
ចេះថៃកិត្តិយសឈ្មោះបវរ   ភាសាអក្សរមិនល្មៀងឃ្លាត
ទំនៀមទំលាប់ពុំរវាត   ប្រពៃណីទៀតឥតបោះបង់ ។
យើងមានកំណើតកើតជាខ្មែរ   ជាតិសាសន៍មួយដែរគួរផ្ចិតផ្ចង់
តាំងចិត្តសន្ដានអោយផូរផង់   ជួយគ្នាតម្រង់ប្លង់សំណៅ ។
ហាត់អាននិយាយភាសាខ្មែរ   សរសេរហូរហែអោយឆ្អិនឆ្អៅ
ទោះបានតិចច្រើនឬខ្លោចឆៅ   ជាជាងស្ងៀមនៅមិនរវល់ ។
ត្រូវចេះចង់ដឹងពីទំលាប់   ទំនៀមទាមជាប់ខំស្វែងយល់
វប្បធម៌ប្រពៃណីនិមល   សាកសួរឫសគល់ពីចាស់ៗ ។

ពីម្តាយឪពុកនៅកៀកក្បែរ លោកត្រៀមចាំតែប្រាប់យ៉ាងច្បាស់
ត្រង់ណារឿងឆ្ងល់កុំអៀនខ្មាស់ ត្រូវឆាប់រហ័សសាកសួរសាំ ។
មានចិត្តស្រលាញ់ពូជពង្សា ជួយជនខេមរារងគ្រោះកម្ម
ជាតិយើងតែមួយចូរចងចាំ កុំមើលបំណាំនាំប្រេះឆា ។
ឈាមខ្មែរដូចគ្នាទោះឆ្ងាយជិត ជួនភ្លឹងងឹតតាមវាសនា
សង្គ្រោះសន្តោសដោយចិន្តា អាណិតមេត្តាជាក់ស្មោះសរ ។
កុំសាងអំនួតអួតចំកោង ឬកក្មេងរាងក្មេងបំប៉ោងក
ប្រមាទមើលងាយអ្នកខ្សត់ក្រ ក្រែងពៀរជាប់តទៅថ្ងៃក្រោយ ។
កុំជិះកុំជាន់អ្នកតូចទាប កោសរូសកិនគាបអ្នកទន់ខ្សោយ
នាំមានវេរាតាមដង្ហោយ កើតភាពថ្ងោះធ្លោយលង់បញ្ហា ។
ប្រកាន់ចិត្តជួយចិត្តស្រោចស្រង់ ចិត្តស្លូតចិត្តត្រង់ចិត្តមេត្តា
ណែនាំដោយបិយវាចា គុណគាប់នោះមហាថ្លៃថ្លាពិត ។
ខ្មែរសាន្តខ្មែរសុខមានមុខមាត់ មិនបែករាយរាត់ខ្វែងគំនិត
ទាំងក្នុងទាំងក្រៅល្អប្រណីត ព្រោះចិត្តខ្មែរគិតចេះយោគយល់ ។
ចេះជួយការកេរ្តិ៍ជាតិខេមរា លើកជាតិសាសនាអោយនិមល
រក្សាការពារគ្រប់មណ្ឌល ខ្មែរពីបុគ្គលដល់សង្គម ។
ហេតុនេះគួរកុំធ្វេសប្រហែស ស្វែងយល់អោយចេះចាត់ផ្គួចផ្គុំ
វប្បធម៌អក្សរសាស្ត្រជាធំ លំអត្រសុំប្រពៃណី ។
ទំនៀមទំលាប់ល្អគ្រប់លក្ខណ៍ ថែទាំអោយជាក់គង់សោភី
នាំគ្នាជ្រោមជ្រែងគ្រប់ទិសទី ជួយស្ទួយមូលមីរថ្កើងពង្សផៅ ។
ជួយលើកតំលៃកេរដូនតា អោយខ្ពស់ថ្លៃថ្លាតកូនចៅ
កេរ្តិ៍ឈ្មោះកិត្តិយសផុតហ្មងសៅ ជាតិសាសន៍ទូទៅកោតស្រលាញ់ ។

អូត្តាវ៉ា ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៥
និពន្ធដោយ ស្វាត សាលឿម